ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

សេចក្តីព្រាង

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង
# ឆ្នាំ ២០១០

# ជំពូកទី ១

## ចំណូល – ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

**មាត្រា ១.–**

ត្រូវបានអនុញ្ញាតសម្រាប់ឆ្នាំ ២០១០ ឱ្យប្រមូលបង់ចូលថវិកាទូទៅរបស់រដ្ឋ នូវពន្ធដារ វិភាគទាន អាករ ផលទុន និង ចំណូលនានា ព្រមទាំង ធ្វើឱ្យសំរេចនូវឧបត្ថម្ភកធនវិនិយោគ និងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "ក" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន ៨.២៩៩.៧៧២,៩ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ÷

+ ចំណូលចរន្ត......................៥.៦៩២.៧៧២,៩ លានរៀល

+ ចំណូលមូលធន......................២.៤១២.០០០ លានរៀល

+ ចំណូលមូលធនក្នុងប្រទេស............៤៨.០០០ លានរៀល

+ ចំណូលមូលធនក្រៅប្រទេស.......២.៣៦៤.០០០ លានរៀល

-មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍

............................៣៦៤.០០០ លានរៀល

-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

..........................២.០០០.០០០ លានរៀល

+ ប្រើប្រាស់បញ្ញើរាជរដ្ឋាភិបាល............១៩៥.០០០ លានរៀល

## មាត្រា ២.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានសម្រាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ត្រូវបានកំណត់ស្មើនឹង ៨.២៩៩.៧៧២,៩ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ÷

+ ចំណាយចរន្ត......................៥.០២៨.៧៧២,៩ លានរៀល

+ ចំណាយមូលធន......................៣.២៧១.០០០ លានរៀល

- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ................................១.១២១.០០០ លានរៀល

  + ដោយមូលនិធិថវិកា.............៧១៣.០០០ លានរៀល

    - គំរោងវិនិយោគផ្ទាល់..........៥១៥.០០០ លានរៀល

    - បដិភាគក្នុងការអនុវត្តគំរោងហិរញ្ញប្បទានក្រៅប្រទេស ...........................១៩៨.០០០ លានរៀល

  +ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ................................៤០៨.០០០ លានរៀល

- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ................................២.០០០.០០០ លានរៀល

- ការទូទាត់ប្រាក់កម្ចី..................១៥០.០០០ លានរៀល

## មាត្រា ៣.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានថវិកា សម្រាប់ចំណាយចរន្តរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ត្រូវបានកំណត់ស្មើនឹង ៥.០២៨.៧៧២,៩ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និង តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និង ទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់នៃឥណទានវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០១០ ដល់ ២០១២ ត្រូវបានកំណត់ស្មើនឹង ៩.៥៤៧.៩៦០ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និង តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគំរោង និង តាមឆ្នាំ ដូចមានចែងក្នុងតារាង "គ១-គ២-គ៣" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៥.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធននៃថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ត្រូវបាន កំណត់ ដូចខាងក្រោម ៖

+ ឥណទានភ្ជាប់សន្យា..................៣.៨៤៧.៣០០ លានរៀល

+ ឥណទានទូទាត់......................៣.២៧១.០០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ៖

+ ឥណទានភ្ជាប់សន្យា..................១.១២១.០០០ លានរៀល

+ ឥណទានទូទាត់.........................១.៦២១.០០៦ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ÷

+ ឥណទានភ្ជាប់សន្យា...................២.៥៧៦.៣០០ លានរៀល

+ ឥណទានទូទាត់.........................២.០០០.០០០ លានរៀល

គ. ការទូទាត់ប្រាក់កម្ចី ÷

+ ឥណទានភ្ជាប់សន្យា.........................១៥០.០០០ លានរៀល

+ ឥណទានទូទាត់...............................១៥០.០០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និង តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និង តាមជំពូកថវិកាដូចមានចែងក្នុងតារាង “ឃ” ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

## មាត្រា ៦.-

តុល្យភាពនៃថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលបានរៀបចំឡើងដោយតារាង “ក” ស្តីពីចំណូលថវិកាទូទៅរបស់រដ្ឋ និង តារាង “ខ” ស្តីពីចំណាយថវិកាទូទៅរបស់រដ្ឋ ត្រូវបានបង្ហាញនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដូចតទៅ ÷

| កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស(+)/ឱនភាព(-) |
|---|---|---|
| **I. ចំណូលក្នុងប្រទេស** | **៥.៧៤០.៧៧២,៩** | |
| ១. ចំណូលចរន្ត | ៥.៦៩២.៧៧២,៩ | |
| ២. ចំណូលមូលធនក្នុងប្រទេស | ៤៨.០០០ | |
| **II. សរុបចំណាយថវិកា** | **៨.១៤៩.៧៧២,៩** | |
| ១. ចំណាយចរន្ត | ៥.០២៨.៧៧២,៩ | |
| ២. ចំណាយមូលធន (មិនគិតការទូទាត់ប្រាក់កម្ចី) | ៣.១២១.០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១.១២១.០០០ | |
| - ដោយមូលនិធិថវិកា | ៧១៣.០០០ | |
| + គំរោងវិនិយោគផ្ទាល់ | ៥១៥.០០០ | |
| + បដិភាគ | ១៩៨.០០០ | |
| - វិនិយោគដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ | ៤០៨.០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ២.០០០.០០០ | |
| **អតិរេកនៃថវិកាចរន្ត (I.១-II.១)** | | **+៦៦៤.០០០** |
| **ឱនភាពសរុបនៃថវិកាទូទៅ (I-II)** | | **-២.៤០៩.០០០** |
| **III. ហិរញ្ញប្បទាននៃឱនភាព** | | **+២.៤០៩.០០០** |
| **១. ហិរញ្ញប្បទានក្រៅប្រទេស** | | **+២.២១៤.០០០** |
| - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ | | +៣៦៤.០០០ |
| - មូលនិធិវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | +២.០០០.០០០ |
| - ការទូទាត់ប្រាក់កម្ចី | | -១៥០.០០០ |
| **២. ហិរញ្ញប្បទានក្នុងប្រទេស** | | **+១៩៥.០០០** |
| - បញ្ញើរដ្ឋាភិបាល | | +១៩៥.០០០ |

# ជំពូកទី ២

# ការខ្ចី និង ការធានារបស់រដ្ឋ

**មាត្រា ៧.-**

អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេមានកម្រិតរហូតដល់ ២០០.០០០.០០០ S.D.R (ពីររយលានអេសដេអ៊ែ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលក្នុងការចុះហត្ថលេខាលើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬ លើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចី និងការធានានេះ ជូនរដ្ឋសភា និង ព្រឹទ្ធសភា រៀងរាល់ ៦ ខែម្តង ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតឱ្យបោះផ្សាយប័ណ្ណរតនាគារក្នុងកម្រិតតទឹកប្រាក់ដែលមានស្តុកចំនួន ១០០.០០០.០០០.០០០៛ (មួយរយពាន់លានរៀល) ដើម្បីដោះស្រាយនូវតំរូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ លក្ខខណ្ឌនៃការលក់ប័ណ្ណរតនាគារនេះត្រូវកំណត់ដោយលិខិតបទដ្ឋានស្រប

**មាត្រា ៨.-**

មិនអនុញ្ញាតឱ្យក្រសួង ឬ ស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬ ចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬ ការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬ ឯកជន ឬ ចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬ តាមឆ្នាំដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និង លក្ខខណ្ឌទាំងឡាយ ដែលច្បាប់នេះបានកំណត់នោះទេ ។

## ជំពូកទី ៣

## និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ

## ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩

**មាត្រា ៩.-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានយល់ព្រមជាគោលការណ៍ដូចខាងក្រោម ៖

ក. ផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅ របស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ចំនួនទឹកប្រាក់ ១៦៥.៣៧៧.៣៦១.៨០០ រៀល ក្នុងនោះ

- សម្រាប់ភាពចាំបាច់ជាបន្ទាន់នៃក្រសួងការពារជាតិ ចំនួន ១៤០.៧៣៥.៣៦១.៨០០ រៀល ។

- សម្រាប់បំពេញដើមទុនឱ្យធនាគារអភិវឌ្ឍន៍ជនបទ ចំនួន ២៤.៦៤២.០០០.០០០ រៀល ។

ខ. យល់ព្រម ឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេបន្ថែមមានកម្រិតរហូតដល់ ២០០ ០០០ ០០០ SDR ( ពីររយលានអេសដេអ៊ែ ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ នឹងត្រូវអនុម័តនូវចំនួនទឹកប្រាក់ជាក់ស្តែងនៃកិច្ចប្រតិបត្តិការចំណាយថវិកា និងការខ្ចីប្រាក់ពីគេបន្ថែមខាងលើនេះ ។

# ជំពូកទី ៤

## ថវិការបស់រាជធានី-ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០

**មាត្រា ១០.-**

ដោយអនុលោមទៅតាមបទបញ្ញត្តិនៃមាត្រា ១៨ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ កញ្ចប់ថវិការួមនៃថវិការបស់រាជធានី-ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ត្រូវបានកំណត់ដូចខាងក្រោមនេះ ÷

+ សរុបចំណូលថវិកា.....................៣២៦.៣៧០ លានរៀល

- សរុបចំណូលចរន្ត....................២១៥.២៥០ លានរៀល

+ ចំណូលសារពើពន្ធ..............១៩៣.៧៥៩ លានរៀល

+ ចំណូលមិនមែនសារពើពន្ធ..........២១.៤៩១ លានរៀល

- ចំណូលមូលធន............................០ លានរៀល

+ ចំណូលមូលធនផ្ទៃក្នុង.....................០ លានរៀល

- ចំណូលឧបត្ថម្ភពីថវិការដ្ឋ...........១១១.១២០ លានរៀល

+ សរុបចំណាយថវិកា..................៣២៦.៣៧០ លានរៀល

- ចំណាយចរន្ត.......................២៤៨.៦៤០ លានរៀល

- ចំណាយមូលធន....................៧៧.៧៣០ លានរៀល

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមរាជធានី-ខេត្តនីមួយៗ ក៏ដូចជាការបែងចែកឥណទានទៅផ្ទៃក្នុងថវិកាជាជំពូក គណនី និងអនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

# ជំពូកទី ៥

# បទប្បញ្ញត្តិស្តីពីពន្ធ និងអាករ

## ផ្នែកទី ១

### ការលើកទឹកចិត្ត

### ក្នុងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ និង ក្នុងវិស័យមូលបត្រ

**មាត្រា ១១.-**

ក្នុងគោលបំណងអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយចីរភាពនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុញ្ញាតឱ្យបង្កើតមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ ។

គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុនេះ ស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ទីតាំងនៃមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ត្រូវបានផ្ដល់ការលើកទឹកចិត្តជូនចំពោះសកម្មភាពអាជីវកម្ម នៅក្នុងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ ដែលរួមមាន ការលើកលែងមួយផ្នែកឬទាំងស្រុងនៃពន្ធគយ និង/ឬពន្ធអាករ ។ ការលើកលែងពន្ធអាករផ្សេងៗនៅក្រោមការលើកទឹកចិត្តនេះ ត្រូវកំណត់មិនឱ្យលើសពីរយៈពេល ៩ (ប្រាំបួន) ឆ្នាំ ។ ប្រភេទសកម្មភាពអាជីវកម្មដែលត្រូវទទួលបានការលើកទឹកចិត្ត និងលក្ខខណ្ឌនៃការលើកទឹកចិត្តនេះ ត្រូវកំណត់លម្អិតដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១២.-**

សម្រាប់អភិវឌ្ឍវិស័យមូលបត្រប្រកបដោយចីរភាព នៅព្រះរាជាណាចក្រកម្ពុជា ការលើកទឹកចិត្តនឹងត្រូវបានផ្ដល់ជូនដល់សកម្មភាពពាក់ព័ន្ធនឹងវិស័យមូលបត្រ ។ ការលើកទឹកចិត្តនេះ រួមមាន ការលើកលែងមួយផ្នែកឬទាំងស្រុងនៃពន្ធអាករដែលត្រូវកំណត់មិនឱ្យលើសពីរយៈពេល ៩ (ប្រាំបួន)

ប្រភេទសកម្មភាពដែលត្រូវទទួលបានការលើកទឹកចិត្ត និង លក្ខខណ្ឌនៃការលើកទឹកចិត្តនេះ ត្រូវកំណត់លម្អិតដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២

## ពន្ធលើអចលនទ្រព្យ

**មាត្រា ១៣.-**

យោងតាមមាត្រា ៧៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ និងក្នុងគោលបំណងវិចារណភាវូបនីយ-កម្មក្នុងការប្រើប្រាស់ដី និង ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើតពន្ធលើអចលនទ្រព្យស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និង ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ។ ពន្ធដែលត្រូវប្រមូលពីអចលនទ្រព្យនេះ តម្រូវតែលើអចលនទ្រព្យដែលមានតម្លៃលើសពី ១០០.០០០.០០០ (មួយរយលាន) រៀល ។

សម្រាប់គោលដៅនៃពន្ធនេះ ពាក្យ “អចលនទ្រព្យ” សំដៅដល់ ដី ផ្ទះ អគារ និង សំណង់ផ្សេងៗ ដែលសង់ភ្ជាប់នឹងដីនោះ ។

ពន្ធនេះត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា ០,១% (សូន្យក្បៀសមួយភាគរយ) លើតម្លៃអចលនទ្រព្យ ។ មូលដ្ឋានគិតពន្ធគឺជាតម្លៃ ដី ផ្ទះ អគារ និង សំណង់ផ្សេងៗ ដែលសង់ភ្ជាប់នឹងដីនោះ ដោយកាត់បន្ថយនូវទឹកប្រាក់ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ។ តម្លៃ ដី ផ្ទះ អគារ

និង សំណង់ផ្សេងៗ ដែលសង់ភ្ជាប់នឹងដីនោះ ត្រូវកំណត់តាមតម្លៃទីផ្សារ ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ដែលបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៤.-**

ពន្ធនេះត្រូវបានលើកលែងចំពោះអចលនទ្រព្យ ដូចខាងក្រោម ៖

ក- អចលនទ្រព្យដែលជាដីធ្លីកសិកម្ម ។

ខ- អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល ។

គ- អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់សហគមន៍ ឬបុគ្គលណាមួយដែល ៖

- ត្រូវបានរៀបចំឡើង និង ដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌
- គ្មានចំណែកណាមួយនៃអចលនទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន

ឃ- អចលនទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មការទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

**មាត្រា ១៥.-**

កម្មសិទ្ធិករនៃអចលនទ្រព្យ ឬអ្នកកាន់កាប់នៃអចលនទ្រព្យ ឬអ្នកទទួលប្រយោជន៍ចុងក្រោយនៃអចលនទ្រព្យ ត្រូវប្រកាស និង បង់ពន្ធលើអចលនទ្រព្យនេះ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣០ ខែ កញ្ញា នៃឆ្នាំនីមួយៗ ជូនរដ្ឋបាលសារពើពន្ធដែលអចលនទ្រព្យនោះស្ថិតនៅ ។

**មាត្រា ១៦.-**

បទប្បញ្ញត្តិស្តីពីវិធាន និង នីតិវិធីសារពើពន្ធ ដែលបានចែងក្នុងជំពូកទី ៥ នៃច្បាប់ស្តីពីសារពើពន្ធ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ និង ច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ និង បទប្បញ្ញត្តិស្តីពីពន្ធដារដែលពាក់ព័ន្ធ ត្រូវយកមកអនុវត្តចំពោះពន្ធលើអចលនទ្រព្យនេះ លើកលែងតែមានការកំណត់ផ្សេង ដែលមានចែងក្នុងបទប្បញ្ញត្តិនៃជំពូកនេះ ។

**មាត្រា ១៧.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញប្រកាសដើម្បីអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យនេះ ។

# ផ្នែកទី ៣'

# ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

**មាត្រា ១៨.-**

ចំនួនប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ដែលបានកំណត់ក្នុងមាត្រា ៧ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស-រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីប្រាក់ពន្ធត្រូវកំណត់ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ចំពោះរថយន្តទេសចរណ៍ ដែលមានកម្លាំងលើសពី ១២ សេះ ឡើងទៅ ត្រូវកំណត់ជាថ្មី ដូចខាងក្រោម ÷

| កម្លាំងសេះរបស់រថយន្តទេសចរណ៍គ្រប់ប្រភេទ | គិតពីឆ្នាំផលិត | |
|---|---|---|
| | ដល់៥ឆ្នាំ | លើសពី៥ឆ្នាំ |
| - កម្លាំងសេះលើសពី ១២សេះ ដល់ ១៧សេះ | ៥០០.០០០៛ | ៣៦០.០០៛ |
| - កម្លាំងសេះលើសពី ១៧សេះ ដល់ ២៤សេះ | ១.៦០០.០០០៛ | ១.២០០.០០០៛ |
| - កម្លាំងលើសពី ២៤សេះ ឡើងទៅ | ២.០០០.០០០៛ | |

# ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២០.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០០៩
ក្នុងសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី៤
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

# ការគ្រប់គ្រងឆ្នាំ ២០១០

## តារាង "ក"

## ចំណូលថវិកាទូទៅរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ២០១០/២០០៩ | |
|---|---|---|---|---|---|---|---|
| | | | | ២០០៩ | ២០១០ | កើន (+) / ថយ (-) | ភាគរយ |
| | | | សរុបរួមចំណូលថវិកា ( I + II ) | 7.169.566,7 | 8.104.772,9 | 935.206,2 | 13,0% |
| | | | I. សរុបចំណូលឆ្លងកាត់តេនាគារជាតិ (ក+ខ) | 5.469.566,7 | 6.104.772,9 | 635.206,2 | 11,6% |
| | | | ក្នុងនោះ ចំណូលក្នុងប្រទេស | 5.134.566,7 | 5.740.772,9 | 606.206,2 | 11,8% |
| | | | ក. សរុបចំណូលចរន្ត (ក្រុមទី១+ ក្រុមទី២) | 5.086.566,7 | 5.692.772,9 | 606.206,2 | 11,9% |
| | | | ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | 5.086.566,7 | 5.692.772,9 | 606.206,2 | 11,9% |
| | | | ប្រភេទទី១: ចំណូលសារពើពន្ធ | 4.276.947,7 | 4.840.596,2 | 563.648,5 | 13,2% |
| 70 | | | ចំណូលសារពើពន្ធក្នុងប្រទេស | 3.154.467,7 | 3.728.276,2 | 573.808,5 | 18,2% |
| | 700 | | ពន្ធលើផលទុន ប្រាក់ចំណេញ និងកំរៃទុន (រូបវន្តបុគ្គល) | 147.216,0 | 252.114,0 | 104.898,0 | 71,3% |
| | | 7001 | ពន្ធលើប្រាក់បៀវត្ស | 111.416,0 | 190.705,0 | 79.289,0 | 71,2% |
| | | 7002 | ពន្ធលើផលទុននៃដីធ្លីផ្ទះសំបែង | 35.800,0 | 61.409,0 | 25.609,0 | 71,5% |
| | 701 | | ពន្ធលើផលទុន ប្រាក់ចំណេញ និងកំរៃទុន (នីតិបុគ្គល) | 599.190,0 | 716.295,0 | 117.105,0 | 19,5% |
| | | 7011 | ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | 45.000,0 | 45.285,0 | 285,0 | 0,6% |
| | | 7012 | ពន្ធលើប្រាក់ចំណេញសហគ្រាសឯកជន | 550.070,0 | 662.280,0 | 112.210,0 | 20,4% |
| | | 7013 | ពន្ធលើផលទុននៃដីធ្លីផ្ទះសំបែង | 4.120,0 | 8.730,0 | 4.610,0 | 111,9% |
| | 702 | | ពន្ធទូទៅលើទ្រព្យសម្បត្តិ និងសេវា | 1.578.967,0 | 1.816.926,0 | 237.959,0 | 15,1% |
| | | 7022 | អាករលើផលរបរ-របបផ្ទៃក្នុង (សហគ្រាសឯកជន) | 15.360,0 | 43.950,0 | 28.590,0 | 186,1% |
| | | 7023 | អាករលើតំលៃបន្ថែម-របបផ្ទៃក្នុង (សហគ្រាសសាធារណៈ) | 23.150,0 | 21.400,0 | -1.750,0 | -7,6% |
| | | 7024 | អាករលើតំលៃបន្ថែម-របបផ្ទៃក្នុង (សហគ្រាសឯកជន) | 710.777,0 | 820.776,0 | 109.999,0 | 15,5% |
| | | 7025 | អាករលើតំលៃបន្ថែម-របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 199.680,0 | 219.440,0 | 19.760,0 | 9,9% |
| | | 7026 | អាករលើតំលៃបន្ថែម-របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 630.000,0 | 711.360,0 | 81.360,0 | 12,9% |
| | 703 | | ពន្ធលើទ្រព្យសម្បត្តិបានកំណត់ | 657.940,0 | 778.030,0 | 120.090,0 | 18,3% |
| | | 7031 | អាករពិសេសលើទំនិញមួយចំនួន-របបផ្ទៃក្នុង | 120.100,0 | 131.150,0 | 11.050,0 | 9,2% |
| | | 7032 | អាករពិសេសលើទំនិញមួយចំនួន-របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 182.400,0 | 241.800,0 | 59.400,0 | 32,6% |
| | | 7033 | អាករពិសេសលើទំនិញមួយចំនួន-របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 355.440,0 | 405.080,0 | 49.640,0 | 14,0% |
| | 704 | | អាករលើសេវាដែលបានកំណត់ | 155.106,0 | 141.617,0 | -13.489,0 | -8,7% |
| | | 7041 | អាករលើកាស៊ីណូ | 77.063,0 | 63.617,0 | -13.446,0 | -17,4% |
| | | 7042 | អាករលើឆ្នោត | 3.262,0 | | -3.262,0 | -100,0% |
| | | 7043 | អាករលើល្បែងភ្នាល់ផ្សេងៗ | 5.224,0 | | -5.224,0 | -100,0% |
| | | 7048 | អាករពិសេសលើសេវាមួយចំនួនផ្សេងៗទៀត | 69.557,0 | 78.000,0 | 8.443,0 | 12,1% |
| | 705 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬ ការអនុវត្តសកម្មភាព | 1.398,7 | 6.979,2 | 5.580,5 | 399,0% |
| | | 7052 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 1.398,7 | 6.979,2 | 5.580,5 | 399,0% |
| | 708 | | បំណុលសារពើពន្ធផ្សេងៗទៀត | 14.650,0 | 16.315,0 | 1.665,0 | 11,4% |

* សរុបរួមចំណូលថវិកាឆ្នាំ ២០១០ នេះ មិនទាន់គិតបញ្ចូល [illegible]

# ការគ្រប់គ្រងឆ្នាំ ២០១០

# តារាង "ក"

# ចំណូលថវិកាទូទៅរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ២០១០/២០០៩ | |
|---|---|---|---|---|---|---|---|
| | | | | ២០០៩ | ២០១០ | កើន (+) / ថយ (-) | ភាគរយ |
| | | 7081 | ពន្ធតែមប្រិ៍ | 3.500,0 | 6.760,0 | 3.260,0 | 93,1% |
| | | 7082 | ការផាកពិន័យ និង ទោសបញ្ញត្តិសារពើពន្ធ | 11.150,0 | 9.555,0 | -1.595,0 | -14,3% |
| **71** | | | **ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស** | **1.122.480,0** | **1.112.320,0** | **-10.160,0** | **-0,9%** |
| | 710 | | ពន្ធ និងអាករលើការនាំចូល | 999.600,0 | 999.700,0 | 100,0 | 0,0% |
| | | 7101 | ពន្ធគយពីការនាំចូល | 541.200,0 | 531.960,0 | -9.240,0 | -1,7% |
| | | 7102 | កំរៃយកមុនពីការងារគយក្នុងការនាំចូល | 60.720,0 | 29.380,0 | -31.340,0 | -51,6% |
| | | 7103 | ពន្ធគយលើផលិតផលតេលសិលា | 238.800,0 | 266.760,0 | 27.960,0 | 11,7% |
| | | 7104 | អាករបន្ថែមលើផលិតផលតេលសិលាសំរាប់ថែទាំផ្លូវថ្នល់ | 150.480,0 | 163.280,0 | 12.800,0 | 8,5% |
| | | 7105 | ផលនៃការលក់ផ្ទៃកគយ | 480,0 | 260,0 | -220,0 | -45,8% |
| | | 7106 | ពិន័យផ្សេងៗលើការនាំចូល | 7.920,0 | 8.060,0 | 140,0 | 1,8% |
| | 711 | | ពន្ធ និង អាករលើការនាំចេញ | 122.880,0 | 112.620,0 | -10.260,0 | -8,3% |
| | | 7111 | អាករលើការនាំចេញឈើ | 4.320,0 | 2.080,0 | -2.240,0 | -51,9% |
| | | 7112 | អាករលើការនាំចេញកៅស៊ូ | 24.960,0 | 13.000,0 | -11.960,0 | -47,9% |
| | | 7114 | អាករលើការនាំចេញផលិតផល និងកសិផលផ្សេងៗ | 3.360,0 | 7.280,0 | 3.920,0 | 116,7% |
| | | 7115 | កំរៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 90.000,0 | 90.000,0 | | |
| | | 7116 | ពិន័យផ្សេងៗលើការនាំចេញ | 240,0 | 260,0 | 20,0 | 8,3% |
| **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | | | | **809.619,0** | **852.176,7** | **42.557,7** | **5,3%** |
| **72** | | | **ផលទុននៃទ្រព្យសម្បត្តិរដ្ឋ** | **124.785,1** | **99.971,7** | **-24.813,4** | **-19,9%** |
| | 720 | | ផលនៃសម្បទាន និងការជួលដីធ្លី | 36.575,4 | 44.333,5 | 7.758,1 | 21,2% |
| | | 7201 | សម្បទានទេសាទ | 8.965,0 | 9.112,0 | 147,0 | 1,6% |
| | | 7202 | សម្បទានព្រៃឈើ | 11.212,0 | 18.724,0 | 7.512,0 | 67,0% |
| | | 7204 | សម្បទានរ៉ែ | 7.232,0 | 8.187,3 | 955,3 | 13,2% |
| | | 7205 | ការជួលដីទំនេរ | 9.166,4 | 8.310,2 | -856,2 | -9,3% |
| | 721 | | ផលទុនពីសហគ្រាសសាធារណៈ | 88.209,7 | 55.638,2 | -32.571,5 | -36,9% |
| | | 7211 | ចំនួនលើសនៃទុនចល័ត | | 0,2 | 0,2 | !!! |
| | | 7212 | ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | 88.200,0 | 55.600,0 | -32.600,0 | -37,0% |
| | | 7213 | ការបង់ប្រាក់រំលស់ | 9,7 | 38,0 | 28,3 | 291,8% |
| **73** | | | **ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិ និងសេវា** | **507.114,9** | **457.896,0** | **-49.218,9** | **-9,7%** |
| | 730 | | ផ្នែកសាធារណៈ រដ្ឋបាល និង សេវាដំណើរការ (រកចំណេញ) | 278.978,2 | 226.426,1 | -52.552,1 | -18,8% |
| | | 7301 | ផលទុនរបស់អាកាសចរស៊ីវិល | 58.405,0 | 52.888,0 | -5.517,0 | -9,4% |
| | | 7303 | ផលទុនពីសកម្មភាពទេសចរណ៍ | 150.070,9 | 100.053,0 | -50.017,9 | -33,3% |
| | | 7304 | ផលទុននៃ[illegible] | 3.090,7 | 2.931,0 | -159,7 | -5,2% |
| | | 7305 | ផលទុនពីប្រៃសណីយ៍ និង ទូរគមនាគមន៍ | 64.824,0 | 67.895,7 | 3.071,7 | 4,7% |

* សរុបរួមចំណូលថវិកាឆ្នាំ ២០១០ នេះ មិនទាន់គិតបញ្ចូល[illegible]

# ការគ្រប់គ្រងឆ្នាំ ២០១០

## តារាង "ក"

## ចំណូលថវិកាទូទៅរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ២០១០/២០០៩ | |
|---|---|---|---|---|---|---|---|
| | | | | ២០០៩ | ២០១០ | កើន (+) / ថយ (-) | ភាគរយ |
| | | 7306 | ផលទុនពីវិទ្យុ និង ទូរទស្សន៍ | 832,2 | 845,5 | 13,3 | 1,6% |
| | | 7307 | ផលទុននៃសេវាផ្គត់ផ្គង់ទឹក | 20,4 | 24,0 | 3,6 | 17,6% |
| | | 7308 | ផលទុនផ្សេងៗទៀត | 1.735,0 | 1.788,9 | 53,9 | 3,1% |
| | 731 | | រដ្ឋបាល និង សេវា ( មិនរកចំណេញ ) | 12.554,9 | 12.088,0 | -466,9 | -3,7% |
| | | 7311 | ការលក់សំភារៈបរិក្ខារ សំភារៈខូចខាត និង សំភារៈសិក្សា | 391,0 | 346,5 | -44,5 | -11,4% |
| | | 7312 | លក់ឯកសារ លតាប័ត្រ និង លិខិតបោះពុម្ពផ្សេងៗ | 11.626,2 | 11.033,5 | -592,7 | -5,1% |
| | | 7313 | ផលនៃការដឹកជញ្ជូនទំនិញ | 29,4 | 5,0 | -24,4 | -83,0% |
| | | 7315 | កំរៃនៃការថែទាំ | 358,3 | 403,0 | 44,7 | 12,5% |
| | | 7316 | ផលបានពីការលក់ទ្រព្យសម្បត្តិកំទិចកំទិ សត្វពាហនៈ | | 100,0 | 100,0 | !!! |
| | | 7318 | ផលពីរដ្ឋបាល និង សេវាផ្សេងៗទៀត | 150,0 | 200,0 | 50,0 | 33,3% |
| | 732 | | ផលពីការគ្រប់គ្រងរដ្ឋបាល | 198.198,1 | 201.271,7 | 3.073,6 | 1,6% |
| | | 7321 | អាករស្ពានទូត (ចំណូលពីលិខិតឆ្លងដែន និង ទិដ្ឋាការ) | 161.660,0 | 162.770,0 | 1.110,0 | 0,7% |
| | | 7323 | ផលលើការបង្កើតសហគ្រាស | 831,4 | 970,0 | 138,6 | 16,7% |
| | | 7324 | ផលពីការបង់សិទ្ធប្រឡង | 412,0 | 860,1 | 448,1 | 108,8% |
| | | 7325 | ផលពីការលក់ស្លាកលេខ | 4.412,8 | 5.298,8 | 886,0 | 20,1% |
| | | 7326 | ចំណូលពីប្រដាប់ភ្លី | 634,5 | 842,0 | 207,5 | 32,7% |
| | | 7327 | សេវាសុរិយោដី និង សេវាសំណង់ | 3.717,0 | 3.554,8 | -162,2 | -4,4% |
| | | 7328 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និង ការគោរពលទដ្ឋាន | 26.530,4 | 26.976,0 | 445,6 | 1,7% |
| | 733 | | ការជួលទ្រព្យសម្បត្តិអចល័ត | 17.383,7 | 18.110,2 | 726,5 | 4,2% |
| | | 7331 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្ដាល | 5.596,0 | 6.923,1 | 1.327,1 | 23,7% |
| | | 7332 | ការជួលសហគ្រាសសាធារណៈនៅខេត្ត-រាជធានី (មន្ទីរជំនាញ) | 2,4 | 109,0 | 106,6 | 4441,7% |
| | | 7333 | ការជួលសំភារៈ និង មធ្យោបាយដឹកជញ្ជូន | 2,4 | 2,4 | | |
| | | 7334 | ការជួលអចលនវត្ថុ ( អសង្ហារិម) | 11.782,9 | 11.075,7 | -707,2 | -6,0% |
| 74 | | | **ផលពីការដាក់ពិន័យ និង ការដាក់ទណ្ឌកម្ម** | **2.269,0** | **2.109,0** | **-160,0** | **-7,1%** |
| | 741 | | ផលពីការដាក់ពិន័យ និង ការដាក់ទណ្ឌកម្ម | 2.269,0 | 2.109,0 | -160,0 | -7,1% |
| 76 | | | **ផលហិរញ្ញវត្ថុ** | **40.000,0** | **40.000,0** | | |
| | 761 | | [illegible] | 40.000,0 | 40.000,0 | | |
| 77 | | | **ផលផ្សេងៗ និង ផលពិសេស** | **135.450,0** | **252.200,0** | **116.750,0** | **86,2%** |
| | 772 | | ផលពីនីងបង្គុំការបង្វិលមូលនិធិសហគ្រាសសាធារណៈ | 130.000,0 | 250.000,0 | 120.000,0 | 92,3% |
| | 775 | | ផលពីការលក់អចលនវត្ថុ | 5.450,0 | 2.200,0 | -3.250,0 | -59,6% |
| | | | **ខ. សរុបចំណូលមិនមែនសារពើពន្ធ (ក្រុមទី១+ក្រុមទី២)** | **383.000,0** | **412.000,0** | **29.000,0** | **7,6%** |
| | | | **ក្រុមទី១:ចំណូលចរន្ត (ប្រភេទទី១+ប្រភេទទី២)** | **383.000,0** | **412.000,0** | **29.000,0** | **7,6%** |
| | | | **ប្រភេទទី១: ចំណូលពីប្រភពផ្ទាល់** | **48.000,0** | **48.000,0** | | |

* សរុបរួមចំណូលថវិកាឆ្នាំ ២០១០ នេះ មិនទាន់គិតពោលការលើកលែង...

# ការគ្រប់គ្រងឆ្នាំ ២០១០

## តារាង "ក"

## ចំណូលថវិកាទូទៅរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ២០១០/២០០៩ | |
|---|---|---|---|---|---|---|---|
| | | | | ២០០៩ | ២០១០ | កើន (+) / ថយ (-) | ភាគរយ |
| 27 | | | **អចលកម្មហិរញ្ញវត្ថុ** | 48.000,0 | 48.000,0 | | |
| | 271 | | ការអោយខ្ចី ( ការសងវិញនូវមូលធន ) | 48.000,0 | 48.000,0 | | |
| **ប្រភេទទី២: ចំណូលពីប្រភពខាងក្រៅ** | | | | 335.000,0 | 364.000,0 | 29.000,0 | 8,7% |
| 13 | | | **ឧបត្ថម្ភធនវិនិយោគ** | 178.000,0 | 284.000,0 | 106.000,0 | 59,6% |
| | 131 | | ឧបត្ថម្ភធនពីទ្វេភាគី | 86.000,0 | 104.000,0 | 18.000,0 | 20,9% |
| | | 1311 | ជប៉ុន | 30.000,0 | 40.000,0 | 10.000,0 | 33,3% |
| | | 1318 | ផ្សេងៗ | 56.000,0 | 64.000,0 | 8.000,0 | 14,3% |
| | 132 | | ឧបត្ថម្ភធនពីពហុភាគី | 92.000,0 | 180.000,0 | 88.000,0 | 95,7% |
| | | 1321 | ធនាគារពិភពលោក | 60.000,0 | 60.000,0 | | |
| | | 1322 | ធនាគារអភិវឌ្ឍន៍អាស៊ី | 32.000,0 | 120.000,0 | 88.000,0 | 275,0% |
| 16 | | | **ការខ្ចី និង បំណុលប្រហាក់ប្រហែល** | 157.000,0 | 80.000,0 | -77.000,0 | -49,0% |
| | 162 | | ការខ្ចីក្រៅប្រទេសពីពហុភាគី | 117.000,0 | 40.000,0 | -77.000,0 | -65,8% |
| | 163 | | ការខ្ចីក្រៅប្រទេសពីទ្វេភាគី | 40.000,0 | 40.000,0 | | |
| **II. សរុបចំណូលវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស** | | | | 1.700.000,0 | 2.000.000,0 | 300.000,0 | 17,6% |
| **ប្រភេទទី២: ចំណូលពីប្រភពខាងក្រៅ** | | | | 1.700.000,0 | 2.000.000,0 | 300.000,0 | 17,6% |
| 13 | | | **ឧបត្ថម្ភធនវិនិយោគ** | 900.000,0 | 1.050.000,0 | 150.000,0 | 16,7% |
| | 131 | | ឧបត្ថម្ភធនពីទ្វេភាគី | 900.000,0 | 1.050.000,0 | 150.000,0 | 16,7% |
| | | 1318 | ផ្សេងៗ | 900.000,0 | 1.050.000,0 | 150.000,0 | 16,7% |
| 16 | | | **ការខ្ចី និង បំណុលប្រហាក់ប្រហែល** | 800.000,0 | 950.000,0 | 150.000,0 | 18,8% |
| | 162 | | ការខ្ចីក្រៅប្រទេសពីពហុភាគី | 800.000,0 | 950.000,0 | 150.000,0 | 18,8% |

* សរុបចំណូលថវិកាឆ្នាំ ២០១០ នេះ មិនទាន់គិតបញ្ចូលការប្រើប្រាស់បញ្ញើរាជរដ្ឋាភិបាលចំនួន ១៩៥.០០០ លានរៀល

## តារាង "ខ"

## ចំណាយថវិកាទូទៅរបស់រដ្ឋ

ឯកតា: លានរៀល

| ក្រសួង-ស្ថាប័ន | សរុបរួមចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុបចំណាយចរន្ត | ប្រភេទ១ មធ្យោបាយសេវា | ប្រភេទទី២ បន្ទុកហិរញ្ញវត្ថុ | ប្រភេទទី៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី៤ ចំណាយផ្សេងៗ | ប្រភេទទី៦ ចំណាយមិនបានគ្រោងទុក | សរុបចំណាយមូលធន | ប្រភេទទី១ ការទូទាត់ប្រាក់កម្ចី | ប្រភេទទី២ អចលកម្ម |
| **សរុបរួមចំណាយ** | 8.299.772,9 | 5.028.772,9 | 3.500.086,2 | 120.000,0 | 995.535,1 | 2.273,6 | 410.878,0 | 3.271.000,0 | 150.000,0 | 3.121.000,0 |
| រដ្ឋបាលកណ្តាល | 7.090.341,7 | 3.819.341,7 | 2.355.284,6 | 120.000,0 | 931.717,1 | 1.462,0 | 410.878,0 | 3.271.000,0 | 150.000,0 | 3.121.000,0 |
| មន្ទីរជំនាញរាជធានី-ខេត្ត | 1.209.431,2 | 1.209.431,2 | 1.144.801,6 | | 63.818,0 | 811,6 | | | | |
| **ក. វិស័យរដ្ឋបាលទូទៅ** | 694.351,9 | 694.351,9 | 534.643,5 | | 159.046,4 | 662,0 | | | | |
| រដ្ឋបាលកណ្តាល | 649.493,9 | 649.493,9 | 489.785,5 | | 159.046,4 | 662,0 | | | | |
| មន្ទីរជំនាញរាជធានី-ខេត្ត | 44.858,0 | 44.858,0 | 44.858,0 | | | | | | | |
| ០១. ព្រះបរមរាជវាំង | 49.473,0 | 49.473,0 | 29.643,0 | | 19.780,0 | 50,0 | | | | |
| ០២. រដ្ឋសភា | 113.629,0 | 113.629,0 | 110.810,0 | | 2.739,0 | 80,0 | | | | |
| ០៣. ព្រឹទ្ធសភា | 32.681,0 | 32.681,0 | 30.701,0 | | 1.900,0 | 80,0 | | | | |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | 7.167,5 | 7.167,5 | 7.139,5 | | 20,0 | 8,0 | | | | |
| ០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី | 190.571,0 | 190.571,0 | 72.471,0 | | 118.000,0 | 100,0 | | | | |
| ០៥.២. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | 2.751,0 | 2.751,0 | 2.751,0 | | | | | | | |
| ០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 5.354,0 | 5.354,0 | 5.331,0 | | | 23,0 | | | | |
| ០៧. ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ | 51.430,0 | 51.430,0 | 50.380,0 | | 1.050,0 | | | | | |
| ២. រដ្ឋបាលកណ្តាល | 51.430,0 | 51.430,0 | 50.380,0 | | 1.050,0 | | | | | |
| ៥. សាលារាជធានី-ខេត្ត | | | | | | | | | | |
| ០៨. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច | 14.997,0 | 14.997,0 | 14.980,0 | | | 17,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 8.730,0 | 8.730,0 | 8.713,0 | | | 17,0 | | | | |
| ៥. មន្ទីរជំនាញរាជធានី-ខេត្ត | 6.267,0 | 6.267,0 | 6.267,0 | | | | | | | |
| ០៩. ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | 69.774,0 | 69.774,0 | 69.057,0 | | 700,0 | 17,0 | | | | |
| ១០. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | 83.653,0 | 83.653,0 | 68.563,0 | | 14.830,0 | 260,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 69.031,0 | 69.031,0 | 53.941,0 | | 14.830,0 | 260,0 | | | | |
| ៥. មន្ទីរជំនាញរាជធានី-ខេត្ត | 14.622,0 | 14.622,0 | 14.622,0 | | | | | | | |
| ១៤. ក្រសួងផែនការ | 22.794,0 | 22.794,0 | 22.784,0 | | 10,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 14.155,0 | 14.155,0 | 14.145,0 | | 10,0 | | | | | |
| ៥. មន្ទីរជំនាញរាជធានី-ខេត្ត | 8.639,0 | 8.639,0 | 8.639,0 | | | | | | | |
| ២៦. ក្រសួងយុត្តិធម៌ | 34.978,0 | 34.978,0 | 34.962,0 | | 10,0 | 6,0 | | | | |
| ១. យុត្តិធម៌ | 14.068,0 | 14.068,0 | 14.062,0 | | | 6,0 | | | | |
| ២. តុលាការកំពូល | 2.369,0 | 2.369,0 | 2.359,0 | | 10,0 | | | | | |
| ៣. សាលាឧទ្ធរណ៍ | 2.218,0 | 2.218,0 | 2.218,0 | | | | | | | |
| ៤. ក្រុមប្រឹក្សានៃអង្គចៅក្រម | 993,0 | 993,0 | 993,0 | | | | | | | |
| ៥. មន្ទីរជំនាញរាជធានី-ខេត្ត | 15.330,0 | 15.330,0 | 15.330,0 | | | | | | | |
| ៣០. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 8.707,4 | 8.707,4 | 8.689,0 | | 1,4 | 17,0 | | | | |
| ៣១. អាជ្ញាធរសវនកម្មជាតិ | 6.392,0 | 6.392,0 | 6.382,0 | | 6,0 | 4,0 | | | | |
| **ខ. វិស័យការពារជាតិ និង សន្តិសុខ** | 1.150.522,0 | 1.150.522,0 | 1.133.693,0 | | 16.829,0 | | | | | |
| ០៦. ក្រសួងការពារជាតិ | 702.472,0 | 702.472,0 | 691.472,0 | | 11.000,0 | | | | | |
| ០៧.១. ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ | 448.050,0 | 448.050,0 | 442.221,0 | | 5.829,0 | | | | | |
| **គ. វិស័យសង្គមកិច្ច** | 1.829.364,8 | 1.829.364,8 | 1.444.807,0 | | 383.546,7 | 1.011,1 | | | | |
| រដ្ឋបាលកណ្តាល | 803.640,8 | 803.640,8 | 465.909,1 | | 337.378,7 | 353,0 | | | | |
| មន្ទីរជំនាញរាជធានី-ខេត្ត | 1.025.724,0 | 1.025.724,0 | 978.897,9 | | 46.168,0 | 658,1 | | | | |
| ១៥. ក្រសួងព័ត៌មាន | 40.912,0 | 40.912,0 | 40.873,0 | | 26,0 | 13,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 30.719,0 | 30.719,0 | 30.680,0 | | 26,0 | 13,0 | | | | |
| ៥. មន្ទីរជំនាញរាជធានី-ខេត្ត | 10.193,0 | 10.193,0 | 10.193,0 | | | | | | | |
| ១៦. ក្រសួងសុខាភិបាល | 600.056,0 | 600.056,0 | 290.851,0 | | 308.814,0 | 391,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 419.716,0 | 419.716,0 | 123.021,0 | | 296.524,0 | 171,0 | | | | |
| ៥. មន្ទីរជំនាញរាជធានី-ខេត្ត | 180.340,0 | 180.340,0 | 167.830,0 | | 12.290,0 | 220,0 | | | | |

# ការគ្រប់គ្រងឆ្នាំ ២០១០

## តារាង "ខ"

## ចំណាយថវិកាចរន្តរបស់រដ្ឋ

ឯកតា:លានរៀល

| ក្រសួង_ស្ថាប័ន | សរុបរួមចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុបចំណាយចរន្ត | ប្រភេទ ១ មធ្យោបាយសេវា | ប្រភេទទី ២ បន្ទុកហិរញ្ញវត្ថុ | ប្រភេទទី ៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី ៤ ចំណាយផ្សេងៗ | ប្រភេទទី ៦ ចំណាយមិនបានគ្រោងទុក | សរុបចំណាយមូលធន | ប្រភេទទី ១ ការទូទាត់ប្រាក់កម្ចី | ប្រភេទទី ២ អចលកម្ម |
| ១៦. ក្រសួងអប់រំ យុវជន និង កីឡា | 824.879,0 | 824.879,0 | 799.511,0 | | 24.848,0 | 520,0 | | | | |
| ១. អប់រំ | 189.548,0 | 189.548,0 | 179.293,0 | | 10.160,0 | 95,0 | | | | |
| ២. ឧត្តមសិក្សា | 41.489,0 | 41.489,0 | 41.039,0 | | 450,0 | | | | | |
| ៣. យុវជន និង កីឡា | 18.085,0 | 18.085,0 | 11.847,0 | | 6.238,0 | | | | | |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 575.757,0 | 575.757,0 | 567.332,0 | | 8.000,0 | 425,0 | | | | |
| ១៨. ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | 26.436,5 | 26.436,5 | 25.826,5 | | 600,0 | 10,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 15.862,0 | 15.862,0 | 15.252,0 | | 600,0 | 10,0 | | | | |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 10.574,5 | 10.574,5 | 10.574,5 | | | | | | | |
| ១៩. ក្រសួងបរិស្ថាន | 19.562,0 | 19.562,0 | 19.374,0 | | 167,0 | 21,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 10.168,0 | 10.168,0 | 9.981,0 | | 167,0 | 20,0 | | | | |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 9.394,0 | 9.394,0 | 9.393,0 | | | 1,0 | | | | |
| ២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | 215.670,9 | 215.670,9 | 185.318,0 | | 30.339,9 | 13,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 16.436,9 | 16.436,9 | 6.587,0 | | 9.839,9 | 10,0 | | | | |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 199.234,0 | 199.234,0 | 178.731,0 | | 20.500,0 | 3,0 | | | | |
| ២៣. ក្រសួងធម្មការ និង សាសនា | 15.194,0 | 15.194,0 | 15.191,0 | | | 3,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 6.434,0 | 6.434,0 | 6.431,0 | | | 3,0 | | | | |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 8.760,0 | 8.760,0 | 8.760,0 | | | | | | | |
| ២៤. ក្រសួងកិច្ចការនារី | 27.908,5 | 27.908,5 | 21.381,4 | | 6.500,0 | 27,1 | | | | |
| ១. រដ្ឋបាលកណ្តាល | 13.547,0 | 13.547,0 | 10.227,0 | | 3.300,0 | 20,0 | | | | |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 14.361,5 | 14.361,5 | 11.154,4 | | 3.200,0 | 7,1 | | | | |
| ៣២. ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | 58.745,9 | 58.745,9 | 46.481,1 | | 12.251,8 | 13,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 41.635,9 | 41.635,9 | 31.551,1 | | 10.073,8 | 11,0 | | | | |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 17.110,0 | 17.110,0 | 14.930,0 | | 2.178,0 | 2,0 | | | | |
| **ឃ. វិស័យសេដ្ឋកិច្ច** | **769.112,2** | **419.112,2** | **386.942,7** | | **31.569,0** | **600,5** | | **350.000,0** | | **350.000,0** |
| រដ្ឋបាលកណ្តាល | 630.263,0 | 280.263,0 | 265.897,0 | | 13.919,0 | 447,0 | | 350.000,0 | | 350.000,0 |
| មន្ទីរជំនាញរាជធានី-ខេត្ត | 138.849,2 | 138.849,2 | 121.045,7 | | 17.650,0 | 153,5 | | | | |
| ០៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | 12.229,0 | 12.229,0 | 11.844,0 | | 375,0 | 10,0 | | | | |
| ១៣. ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | 17.413,5 | 17.413,5 | 15.427,5 | | 1.960,0 | 26,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 7.327,0 | 7.327,0 | 7.192,0 | | 110,0 | 25,0 | | | | |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 10.086,5 | 10.086,5 | 8.235,5 | | 1.850,0 | 1,0 | | | | |
| ១៥. ក្រសួងពាណិជ្ជកម្ម | 52.867,0 | 52.867,0 | 49.576,0 | | 3.278,0 | 13,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 44.397,0 | 44.397,0 | 41.112,0 | | 3.278,0 | 7,0 | | | | |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 8.470,0 | 8.470,0 | 8.464,0 | | | 6,0 | | | | |
| ១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | 87.485,0 | 87.485,0 | 71.917,0 | | 15.393,0 | 175,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 54.779,0 | 54.779,0 | 46.846,0 | | 7.793,0 | 140,0 | | | | |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 32.706,0 | 32.706,0 | 25.071,0 | | 7.600,0 | 35,0 | | | | |
| ២០. ក្រសួងអភិវឌ្ឍន៍ជនបទ | 173.156,0 | 83.156,0 | 83.077,0 | | | 79,0 | | 90.000,0 | | 90.000,0 |
| ១. រដ្ឋបាលកណ្តាល | 147.580,0 | 57.580,0 | 57.525,0 | | | 55,0 | | 90.000,0 | | 90.000,0 |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 25.576,0 | 25.576,0 | 25.552,0 | | | 24,0 | | | | |
| ២២. ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | 39.821,5 | 39.821,5 | 37.943,0 | | 1.860,0 | 18,5 | | | | |
| ១. រដ្ឋបាលកណ្តាល | 32.845,0 | 32.845,0 | 30.970,0 | | 1.860,0 | 15,0 | | | | |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 6.976,5 | 6.976,5 | 6.973,0 | | | 3,5 | | | | |
| ២៥. ក្រសួងសាធារណការ និង ដឹកជញ្ជូន | 222.139,0 | 32.139,0 | 31.950,5 | | 50,0 | 138,5 | | 190.000,0 | | 190.000,0 |
| ១. រដ្ឋបាលកណ្តាល | 202.623,0 | 12.623,0 | 12.498,0 | | 50,0 | 75,0 | | 190.000,0 | | 190.000,0 |
| ៤. មន្ទីរជំនាញរាជធានី-ខេត្ត | 19.516,0 | 19.516,0 | 19.452,5 | | | 63,5 | | | | |

## ការគ្រប់គ្រងឆ្នាំ ២០១០

## តារាង "ខ"

## ចំណាយថវិកាទូទៅរបស់រដ្ឋ

ឯកតា:លានរៀល

| ក្រសួង-ស្ថាប័ន | សរុបរួមចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុបចំណាយចរន្ត | ប្រភេទ ១ មធ្យោបាយសេវា | ប្រភេទទី ២ បន្ទុកហិរញ្ញវត្ថុ | ប្រភេទទី ៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី ៤ ចំណាយផ្សេងៗ | ប្រភេទទី ៦ ចំណាយមិនបានគ្រោងទុក | សរុបចំណាយមូលធន | ប្រភេទទី ១ ការទូទាត់ប្រាក់កម្ចី | ប្រភេទទី ២ អចលកម្ម |
| ២៧. ក្រសួងទេសចរណ៍ | 30.330,0 | 30.330,0 | 29.919,7 | | 400,0 | 10,3 | | | | |
| ១. រដ្ឋបាលកណ្តាល | 23.052,0 | 23.052,0 | 22.645,0 | | 400,0 | 7,0 | | | | |
| ៥. មន្ទីរជំនាញរាជធានី-ខេត្ត | 7.278,0 | 7.278,0 | 7.274,7 | | | 3,3 | | | | |
| ២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | 26.875,7 | 26.875,7 | 26.854,7 | | | 21,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 15.065,0 | 15.065,0 | 15.045,0 | | | 20,0 | | | | |
| ៥. មន្ទីរជំនាញរាជធានី-ខេត្ត | 11.810,7 | 11.810,7 | 11.809,7 | | | 1,0 | | | | |
| ២៩. ក្រសួងធនធានទឹក និង ឧតុនិយម | 106.795,5 | 36.795,5 | 28.433,3 | | 8.253,0 | 109,2 | | 70.000,0 | | 70.000,0 |
| ១. រដ្ឋបាលកណ្តាល | 90.366,0 | 20.366,0 | 20.220,0 | | 53,0 | 93,0 | | 70.000,0 | | 70.000,0 |
| ៥. មន្ទីរជំនាញរាជធានី-ខេត្ត | 16.429,5 | 16.429,5 | 8.213,3 | | 8.200,0 | 16,2 | | | | |
| **៤៤. ចំណាយមិនទាន់បែងចែក** | **3.856.422,0** | **935.422,0** | | **120.000,0** | **404.544,0** | | **410.878,0** | **2.921.000,0** | **150.000,0** | **2.771.000,0** |
| - ចំណាយចរន្តក្នុងការអនុវត្តគម្រោង | 151.000,0 | 151.000,0 | | | 151.000,0 | | | | | |
| - បន្ទុកហិរញ្ញវត្ថុ | 120.000,0 | 120.000,0 | | 120.000,0 | | | | | | |
| - ឧបត្ថម្ភរាជធានី-ខេត្ត និង ឃុំ-សង្កាត់ | 253.544,0 | 253.544,0 | | | 253.544,0 | | | | | |
| - ចំណាយមិនបានគ្រោងទុក | 410.878,0 | 410.878,0 | | | | | 410.878,0 | | | |
| - ការទូទាត់ប្រាក់កម្ចី | 150.000,0 | | | | | | | 150.000,0 | 150.000,0 | |
| - គំរោងវិនិយោគ | 165.000,0 | | | | | | | 165.000,0 | | 165.000,0 |
| - បដិភាគវិនិយោគ | 198.000,0 | | | | | | | 198.000,0 | | 198.000,0 |
| - វិនិយោគដោយមូលនិធិទ្រទ្រង់ថវិកា | 408.000,0 | | | | | | | 408.000,0 | | 408.000,0 |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 2.000.000,0 | | | | | | | 2.000.000,0 | | 2.000.000,0 |

# ការគ្រប់គ្រងឆ្នាំ ២០១០

## តារាង "គ១"

## វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:ពាន់ដុល្លារអាមេរិក

| លេខគម្រោង | ឈ្មោះគម្រោង | តំលៃគម្រោង | កម្រិតទុនវិនិយោគចែកតាមឆ្នាំ | | | |
|---|---|---|---|---|---|---|
| | | | ២០១០ | ២០១១ | ២០១២ | សរុប ៣ ឆ្នាំ |
| | **សរុបរួម** | 7.367.066 | 761.269 | 767.505 | 800.004 | 2.328.778 |
| **ក្រសួងសុខាភិបាល** | | 1.019.545 | 122.565 | 127.351 | 134.711 | 384.627 |
| 82 | កម្មវិធីប្រយុទ្ធនឹងជំងឺរបេង | 135.000 | 8.203 | 8.327 | 8.519 | 25.049 |
| 83 | ការប្រយុទ្ធនឹងជំងឺគ្រុនចាញ់ គ្រុនឈាម | 82.760 | 10.954 | 11.955 | 13.340 | 36.249 |
| 84 | កែទម្រង់ការចែកចាយឱសថ និងសម្ភារៈ បរិក្ខារពេទ្យ | 348.757 | 39.258 | 42.977 | 47.075 | 129.310 |
| 86 | កម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគ | 88.396 | 11.668 | 10.222 | 12.616 | 34.506 |
| 87 | ការស្តារមន្ទីរពេទ្យជាតិ | 160.970 | 12.341 | 12.643 | 11.062 | 36.046 |
| 426 | ត្រួតពិនិត្យគ្រប់គ្រងចំណីអាហារ និងថ្នាំសង្កូវ | 2.461 | 611 | 307 | 326 | 1.244 |
| 701 | អភិវឌ្ឍន៍ឱសថបុរាណ | 8.318 | 1.162 | 1.407 | 1.596 | 4.165 |
| 962 | គម្រោងគ្រប់គ្រងជំងឺកុមារ (IMCI) | 6.904 | 1.300 | 1.300 | 1.300 | 3.900 |
| 1024 | កម្មវិធីត្រួតពិនិត្យ និងអន្តរាគមន៍សុខភាពសាធារណៈ | 25.059 | 1.368 | 1.363 | 1.377 | 4.108 |
| 1470 | ពង្រឹងប្រព័ន្ធសុខាភិបាល | 160.920 | 35.700 | 36.850 | 37.500 | 110.050 |
| **ក្រសួងអប់រំ យុវជន និងកីឡា** | | 240.303 | 49.165 | 47.736 | 39.150 | 136.051 |
| 876 | ការអប់រំមូលដ្ឋាន និងបណ្តុះបណ្តាលគ្រូបង្រៀននៅ ខេត្តសៀមរាប ឧត្តរមានជ័យ និងកំពង់ចាម | 22.060 | 3.919 | | | 3.919 |
| 1063 | គម្រោងទ្រទ្រង់វិស័យអប់រំនៅកម្ពុជា | 39.000 | 4.695 | | | 4.695 |
| 1071 | កម្មវិធីពង្រីកការអប់រំមូលដ្ឋានដំណាក់ទី ២ | 27.700 | 8.651 | 9.019 | 9.865 | 27.535 |
| 1074 | កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំលើកទី ២ | 25.000 | | | | |
| 1075 | គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សា | 33.580 | | | | |
| 1333 | កម្មវិធីផ្តល់អាហារសម្រន់ពេលព្រឹក និងរបបអង្ករយកទៅផ្ទះ | 29.576 | 18.514 | 18.814 | | 37.328 |
| 1508 | លើកកម្ពស់គុណភាពអប់រំ | 33.380 | 11.428 | 11.159 | 10.291 | 32.878 |
| 1066 | សាងសង់ផ្ទះសម្រាប់គ្រូមធ្យមសិក្សា | 15.726 | 500 | 4.000 | 11.000 | 15.500 |
| 1342 | សាងសង់អន្តេវាសិកដ្ឋានសម្រាប់សិស្សមធ្យមសិក្សា | 10.824 | 500 | 4.000 | 6.300 | 10.800 |
| 1416 | កែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា | 2.475 | 575 | 474 | 1.426 | 2.475 |
| 1418 | អភិវឌ្ឍន៍កម្មវិធីបង្រៀនគណិតវិទ្យានៅកម្ពុជា | 580 | 213 | 185 | 182 | 580 |
| 1419 | គម្រោងបច្ចេកទេសសម្រាប់ជំរុញការស្រាវជ្រាវវិទ្យាសាស្ត្រ | 296 | 155 | 70 | 71 | 296 |
| 1420 | កែលម្អទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការស្តីពីការអប់រំ | 106 | 15 | 15 | 15 | 45 |
| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | 410.581 | 58.472 | 84.009 | 165.250 | 307.731 |

សំគាល់: តំលៃចាំសាទពីក្រសួង-ស្ថាប័នខាង។ ប្រភពព័ត៌មាន:ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈក្រសួងផែនការ

# ការគ្រប់គ្រងឆ្នាំ ២០១០

## តារាង "គ១"

## វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:ពាន់ដុល្លារអាមេរិក

| លេខគម្រោង | ឈ្មោះគម្រោង | តំលៃគម្រោង | កម្រិតមូលនិធិយោគចែកតាមឆ្នាំ | | | |
|---|---|---|---|---|---|---|
| | | | ២០១០ | ២០១១ | ២០១២ | សរុប ៣ ឆ្នាំ |
| 1148 | គម្រោងអភិវឌ្ឍវិស័យកសិកម្ម | 5.880 | | | | |
| 1152 | គម្រោងស្តារឡើងវិញលើវិស័យសេដ្ឋកិច្ច-សង្គមកិច្ច នៅខេត្តភាគពាយ័ព្យ (អេក្លូសូន) | 31.879 | 16.882 | | | 16.882 |
| 1158 | គម្រោងស្រាវជ្រាវវារីវប្បកម្ម | 86 | 17 | | | 17 |
| 1159 | គម្រោងចិញ្ចឹមសត្វ កម្ពុជា-អឺរ៉ុប | 6.176 | 1.735 | | 236 | 1.971 |
| 1162 | លើកកម្ពស់រុក្ខកម្មតាមសហគមន៍ | 2.005 | 401 | | 401 | 802 |
| 1202 | គម្រោងកាត់បន្ថយភាពក្រីក្រនៅខេត្តស្វាយរៀង និងព្រៃវែង | 17.500 | 3.005 | 5.200 | | 8.205 |
| 134 | ពង្រីកការដាំកៅស៊ូ | 6.776 | 532 | 3.609 | 2.635 | 6.776 |
| 144 | ស្រាវជ្រាវកសិផល និងផលិតផលគ្រាប់ពូជ | 20.200 | 3.000 | 6.000 | 11.100 | 20.100 |
| 151 | សាងសង់ការិយាល័យតាមដានការនេសាទ | 1.250 | 200 | 200 | 800 | 1.200 |
| 152 | ស្តារឡើងវិញវិទ្យាស្ថានសិក្សាពីសមុទ្រ | 8.000 | 500 | 1.500 | 6.000 | 8.000 |
| 157 | សំណើសុំរំកាំសាំង ថ្នាំ និងឧបករណ៍ | 221 | 11 | 100 | 110 | 221 |
| 161 | អភិវឌ្ឍមជ្ឈមណ្ឌលចិញ្ចឹមគោ ក្របី | 9.165 | 200 | 2.265 | 6.700 | 9.165 |
| 170 | ការរៀបចំ និងគ្រប់គ្រងសត្វព្រៃ | 3.420 | 100 | 12 | 2.500 | 2.612 |
| 174 | សាងសង់អាគារបម្រើឱ្យវិស័យកសិកម្ម | 8.500 | 1.000 | 4.000 | 3.500 | 8.500 |
| 175 | លើកកម្ពស់ស្ថានីយស្រាវជ្រាវ | 3.390 | 577 | 1.467 | 1.242 | 3.286 |
| 183 | គ្រប់គ្រងព្រៃបម្រុងទុកសម្រាប់សត្វស្លាប | 2.000 | 50 | 100 | 100 | 250 |
| 216 | ការកែលម្អថ្មីនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 12.500 | 1.000 | 4.500 | 7.000 | 12.500 |
| 229 | សិក្សាសត្វស្លាបទឹក | 1.000 | 100 | 120 | 30 | 250 |
| 302 | សាងសង់ជួសជុលអាគារមន្ទីរកសិកម្មខេត្ត-រាជធានី | 2.112 | 100 | 300 | 400 | 800 |
| 328 | គម្រោងគ្រប់គ្រងព្រៃព្រែកទឹកសាប | 14.600 | 250 | 500 | 500 | 1.250 |
| 329 | ស្ថាបនាមូលដ្ឋានអភិរក្សសត្វព្រៃនៅឧទ្យានភ្នំគាម៉ៅ | 426 | 100 | 59 | 59 | 218 |
| 333 | បង្ក្រាបបទល្មើសសត្វព្រៃ | 257 | 20 | 73 | 73 | 166 |
| 501 | ជួសជុលរចនាសម្ព័ន្ធស្ថានីយគោកគ្រប់ និងព្រៃផ្តៅ | 194 | 72 | 109 | | 181 |
| 514 | អភិរក្សការគ្រប់គ្រង និងអភិវឌ្ឍន៍ផលផល | 13.561 | 2.000 | 3.000 | 8.000 | 13.000 |
| 520 | ផ្ទះបង្ហាញផលកសិកម្មកំពង់ចាម | 15.414 | 200 | 2.000 | 13.200 | 15.400 |
| 521 | ស្ថានីយបង្កាត់ពូជកៅស៊ូរំលែងសិប្បនិម្មិត | 91 | 33 | 58 | | 91 |
| 523 | បង្កើតស្ថានីយស្រាវជ្រាវវារីវប្បកម្មសមុទ្រ | 8.000 | 500 | 2.500 | 5.000 | 8.000 |
| 524 | ស្ថានីយស្រាវជ្រាវវារីវប្បកម្មទឹកសាប ទឹកភ្លាប | 15.535 | 500 | 1.500 | 13.000 | 15.000 |
| 617 | ការស្រាវជ្រាវលើការគ្រប់គ្រងជញ្ជាតិ | 417 | 89 | 115 | 213 | 417 |

សំគាល់: តំលៃបាន់ស្មានពីក្រសួង-ស្ថាប័ននានា ។ ប្រភពព័ត៌មាន:ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈក្រសួងផែនការ

# ការគ្រប់គ្រងឆ្នាំ ២០១០

## តារាង "គ១"

## វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:ពាន់ដុល្លារអាមេរិក

| លេខ គម្រោង | ឈ្មោះគម្រោង | តំលៃ គម្រោង | កម្រិតទុនវិនិយោគចែកតាមឆ្នាំ | | | |
|---|---|---|---|---|---|---|
| | | | ២០១០ | ២០១១ | ២០១២ | សរុប ៣ ឆ្នាំ |
| 619 | ជួសជុលមជ្ឈមណ្ឌលបច្ចេកទេសកសិកម្មទួលសំរោង | 25.000 | 4.000 | 3.000 | 18.000 | 25.000 |
| 630 | ផលិតវ៉ាក់សាំង | 400 | 222 | 39 | 39 | 300 |
| 686 | ការបង្ហាញលើក្សេត្រសាស្រ្តបសុសត្វ និងការចិញ្ចឹមត្រី | 1.900 | 100 | 1.400 | 400 | 1.900 |
| 694 | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម | 24.700 | 996 | 8.763 | 14.709 | 24.468 |
| 750 | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំនៅសកលវិទ្យាល័យភូមិន្ទកសិកម្ម | 24.100 | 6.000 | 6.000 | 12.000 | 24.000 |
| 751 | ផ្សព្វផ្សាយបច្ចេកវិជ្ជាគ្រឿងយន្តកសិកម្ម | 10.000 | 340 | 284 | 9.200 | 9.824 |
| 771 | ការគ្រប់គ្រងព្រៃឈើអាងទន្លេមេពង្គ | 1.610 | 200 | 200 | 200 | 600 |
| 810 | ផលិតផលកសិកម្ម និងកសិពាណិជ្ជកម្ម | 6.500 | 90 | 1.050 | 5.000 | 6.140 |
| 816 | ពង្រឹងទីផ្សារបសុសត្វ | 300 | 80 | 90 | 130 | 300 |
| 825 | ការអភិរក្សទប់ស្កាត់ការខ្សោះជីវជាតិដី | 3.500 | 428 | 2.800 | 132 | 3.360 |
| 906 | បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវសាកវប្បកម្មកប់ស្រូវ | 25.000 | 4.000 | 9.400 | 11.500 | 24.900 |
| 907 | ការបង្ក្រាបការរុករានទន្ទ្រានព្រៃឈើ | 10.000 | 200 | 500 | 850 | 1.550 |
| 988 | គម្រោងដាំឈើ និងដាំឈើឡើងវិញចំនួន ២.០០០ ហត | 1.474 | 200 | 200 | 200 | 600 |
| 992 | សាងសង់ស្ថានីយស្រាវជ្រាវគ្រាប់ពូជ និងដាំដើមឈើ | 100 | 25 | 25 | 50 | 100 |
| 1029 | បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្ម អូរសណ្ដាស់ | 402 | 144 | 137 | 121 | 402 |
| 1034 | ការអភិវឌ្ឍគុណភាពផ្នែកអនុវត្ត និងលើកកម្ពស់បទដ្ឋានពិសោធន៍នៅ សកលវិទ្យាល័យភូមិន្ទកសិកម្ម ចំការដូង | 543 | 182 | 182 | 179 | 543 |
| 1036 | ការអភិវឌ្ឍការចិញ្ចឹមសត្វ | 8.489 | 639 | 3.500 | 4.350 | 8.489 |
| 1037 | ការគ្រប់គ្រងធនធានទឹកចម្រុះសម្រាប់ប្រពលវប្បកម្មដំណាំ និងការផ្លាស់ប្តូរ ប្រព័ន្ធកសិកម្មនៅខេត្តកំពង់ឆ្នាំង | 6.081 | 500 | 500 | 600 | 1.600 |
